**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 21-Oct-2015, 14:13
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល: **សម្ងាត់/Confidential**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញាលើកាលវិភាគសម្រាប់សវនាការលើបណ្ដឹងសាទុក្ខ សំណុំរឿង០០២/០១**

---

ដាក់ដោយ៖

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

ផ្ញើជូន៖

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C.N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**ជនជាប់ចោទ៖**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដី៖**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

<u>ចម្លងជូន</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ពេជ អង្គ

Marie GUIRAUD

# I. សេចក្តីសង្ខេប

១. នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូល (“អជតក”) បានចេញដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១[1]។ ដីកានោះចែងអំពីកាលវិភាគសម្រាប់សវនាការ ដោយរួមមានប្រធានបទទូទៅចំនួនប្រាំមួយ ដែលត្រូវដោះស្រាយ និងពេលវេលាបែងចែកដល់ភាគីនីមួយៗសម្រាប់ប្រធានបទនីមួយៗ[2]។ អជតក បានអញ្ជើញឱ្យភាគីនានាដាក់សេចក្តីសង្កេតរបស់ខ្លួនលើកាលវិភាគនោះ ប្រសិនបើមាន ត្រឹមថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥។ អជតក ក៏បានជូនដំណឹងផងដែរដល់ភាគីនានាថា អង្គជំនុំជម្រះនឹងបញ្ជាក់នៅក្នុងសេចក្តីសម្រេចនៅពេលក្រោយលើបញ្ហាជាក់លាក់នានា ដែលអង្គជំនុំជម្រះយល់ថាភាគីទាំងឡាយត្រូវផ្តោតក្នុងអំឡុងពេលធ្វើសារណាផ្ទាល់មាត់[3]។ ពេលនេះសហព្រះរាជអាជ្ញាសូមដាក់សេចក្តីសង្កេតរបស់ខ្លួនលើកាលវិភាគនោះ ដោយរួមបញ្ចូលសំណើសុំពេលវេលាបន្ថែមដើម្បីធ្វើសារណាលើប្រធានបទពីរក្នុងចំណោមប្រធានបទទាំងប្រាំមួយដែលត្រូវបានបញ្ជាក់ដោយ អជតក។

២. វិធានផ្ទៃក្នុងចែងថាកិច្ចដំណើការនីតិវិធីនៅ អវតក “ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ”[4]។ យុត្តិសាស្ត្រពីតុលាការអន្តរជាតិដទៃផ្សេងទៀតក៏ទទួលស្គាល់សិទ្ធិរបស់ភាគីទាំងអស់ ចំពោះកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធ៌មផងដែរ[5]។ វិធានផ្ទៃក្នុងក៏ចែងផងដែរថាសវនាការលើបណ្តឹងសាទុក្ខត្រូវធ្វើជាសាធារណៈ[6]។

---

[1] **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ (“ដីកា”)។

[2] **F30.1** កាលវិភាគសម្រាប់សវនាការ (ឧបសម្ព័ន្ធ ក ភ្ជាប់ទៅនឹងដីកា) (“ឧបសម្ព័ន្ធ ក”)។

[3] ដីកា ទំព័រ៤។

[4] វិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង។

[5] *សូមមើល ឧ.* ខាងក្រោម៖ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY៖ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hardinaj,* IT-04-84-A សាលដីកា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៦ (“... សេចក្តីសម្រេចនេះជាថ្មីម្តងទៀត បានកំណត់អាទិភាពការពិចារណាផ្នែកសម្ភារៈមិនសមស្របចំពោះសិទ្ធិរបស់អយ្យការក្នុងការទទួលបានសវនាការដ៏យុត្តិធម៌។”) & កថាខណ្ឌ៤៩ (“ដោយសារតែសារៈសំខាន់ជាសក្តានុពលនៃសាក្សីទាំងអស់នេះចំពោះរឿងក្តីរបស់អយ្យការ អង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ឃើញថា ក្នុងបរិបទនៃរឿងក្តីនេះ កំហុសនោះបានធ្វើឱ្យចុះខ្សោយដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបានធានាដោយលក្ខន្តិកៈ និងវិធាននានា ហើយនាំឱ្យមានភាពមិនយុត្តិធម៌”)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Prlić និងគូកន,* IT-04-74-AR73.4, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អយ្យការ ទាក់ទងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែល

៣. ខណៈដែលកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតាមគោលការណ៍ចំពោះមុខ មិនចាំបាច់តម្រូវថា ភាគីនីមួយៗមានចំនួនទំព័រដូចគ្នាបេះបិតសម្រាប់ការដាក់ឯកសារ ឬពេលវាលាដូចគ្នាដើម្បីធ្វើសារណាផ្ទាល់មាត់នោះ វាតម្រូវថាភាគីនីមួយៗមានឱកាសសមស្រប និងមានអត្ថន័យពេញលេញដើម្បីធ្វើសារណារបស់ខ្លួន។ អ្វីដែលបង្កើតឱ្យមានឱកាសដ៏មានអត្ថន័យពេញលេញក្នុងការធ្វើសារណានោះ នឹងអាស្រ័យលើកាលៈទេសៈនានានៃរឿងក្ដីដែលផ្ដល់ជូន ដោយរួមបញ្ចូលជាពិសេសភាពស្មុគស្មាញផ្នែកច្បាប់ និងផ្នែកអង្គហេតុនៃបញ្ហានានាដែលកំពុងដោះស្រាយ។

៤. ទាក់ទងទៅនឹងប្រធានបទចំនួនពីរ គឺការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ និងឧក្រិដ្ឋកម្មនានាដែលជនជាប់ចោទត្រូវបានផ្ដន្ទាទោស សហព្រះរាជអាជ្ញាយល់ឃើញថា ដោយសារតែទឡ្ហីករណ៍មួយចំនួនធំនៃបណ្ដឹងសាទុក្ខស្ថិតក្នុងប្រធានបទទាំងនេះ និងភាពស្មុគស្មាញផ្នែកអង្គហេតុ និងផ្នែកច្បាប់នៃបញ្ហានានាដែលកំពុងដោះស្រាយ សហព្រះរាជអាជ្ញាទាមទាឱ្យមានពេលវេលាបន្ថែមដើម្បីធ្វើសារណារបស់ខ្លួន។

*ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលជនជាប់ចោទ*

---

កាត់បន្ថយពេលវេលាសម្រាប់រឿងក្ដីអយ្យការ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២៩៩៧ កថាខណ្ឌ១៤ (“គោលការនៃសមភាពនៃអំណាចបានបរាជ័យនៅក្នុងការធានាឱ្យមានសវនាការដ៏យុត្តិធម៌ ក្រោមលក្ខខ័ណ្ឌ: អនុវត្តចំពោះអយ្យការក៏ដូចជាផ្នែកការពារក្ដីផងដែរ”)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Aleksovski,* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញាលើភាពអាចទទួលយកបាននៃភស្តុតាង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ២៥ (“ការអនុវត្តនៃសវនាការដ៏យុត្តិធម៌នេះដែលគាំទ្រដល់ភាគីទាំងពីរអាចយល់បានដោយសារតែអយ្យការធ្វើតំណាងឱ្យ និងក្នុងផលប្រយោជន៍របស់សហគមន៍ ដោយរួមបញ្ចូលទាំងជនរងគ្រោះនៃបទល្មើសដែលត្រូវបានចោទប្រកាន់ (នៅក្នុងរឿងក្ដីនានានៅចំពោះមុខអង្គជំនុំជម្រះ រដ្ឋអាជ្ញាធ្វើកិច្ចតំណាងឱ្យសហគមអន្តរជាតិ”)។ គោលការណ៍នៃសមភាពមិនប៉ះពាល់ទៅនឹងប្រវត្តិនៃការការពារជាមូលដ្ឋានទាំងនោះទេ។ ប្រសិនជាយល់បែបនេះវាពិបាកក្នុងការមើលឃើញថាតើសវនាការមួយអាចត្រូវបានចាត់ទុកថាយុត្តិធម៌ដោយរបៀបណានោះទេ ក្នុងករណីដែលជនជាប់ចោទត្រូវបានគាំទ្រ ដោយធ្វើឱ្យខូចប្រយោជន៍របស់អយ្យការហួសពីការព្រមព្រៀងតាមដ៏តឹងរឹងជាមួយនឹងការការពារជាមូលដ្ឋានទាំងនោះ”)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Tadić,* IT-94-1-A, សាលដីកា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ៤៨។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC៖ *ស្ថានភាពនៅក្នុងសារធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ICC-01/04 សេចក្ដីសម្រេចលើពាក្យសុំរបស់អយ្យការសុំការអនុញ្ញាតប្ដឹងសាទុក្ខសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ លើពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៃ VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5, និង VPRS 6 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៣៨ (“តាមការយល់ឃើញរបស់អង្គជំនុំជម្រះ ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីរួមមាន ការគោរពសិទ្ធិជានីតិវិធីរបស់រដ្ឋអាជ្ញា មេធាវីការពារក្ដី និងជនរងគ្រោះ ដូចដែលត្រូវបានធានាដោយលក្ខខ័ណ្ឌកៈពាក់ព័ន្ធ [។]”)។ ។

[6] វិធាន១០៩(១) នៃវិធានផ្ទៃក្នុង។

៥. បញ្ហានានាទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលជនជាប់ចោទ គឺមានលក្ខណៈស្មុគស្មាញ ខាងអង្គហេតុ និងខាងអង្គច្បាប់។ ការវិភាគអំពីការទទួលខុសត្រូវជាបុគ្គលជនជាប់ចោទ តម្រូវជាចាំបាច់ឲ្យមានការវាយតម្លៃខ្ពស់លើវិធីដែលផ្នែកផ្សេងៗជាច្រើននៃសាលក្រម និងការយល់ឃើញលើអង្គហេតុផ្សេងៗជាច្រើន មកបញ្ចូលគ្នាដើម្បីគាំទ្រសេចក្ដីសន្និដ្ឋានចុងក្រោយមួយ ក៏ដូចជាការយល់ឃើញលើសំណុំភ័ស្តុតាងដ៏ច្រើន ដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែក។ ការណ៍នោះ អាចផ្ទុយទៅនឹងផ្នែកប្រធានបទផ្សេងៗទៀត (ជាឧទាហរណ៍ បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវខាងសហឧក្រិដ្ឋកម្មរួម ដែលគេបានស្គាល់ថាជា JCE III) ដែលទាក់ទងនឹងបញ្ហានានាដែលត្រូវការដោះស្រាយ មានដែនកំណត់ និងមានកម្រិត។

៦. ដោយសារតែភាពស្មុគស្មាញ និងសារៈសំខាន់នៃបញ្ហានានា ហើយនិងទំហំនៃកំណត់ត្រាជាភ័ស្តុតាង គេមិនមានការភ្ញាក់ផ្អើលទេថា ការទទួលខុសត្រូវជាបុគ្គល គឺជាលក្ខណៈស្នូលនៃសារណាបណ្ដឹងសាទុក្ខទាំងពីររបស់ជនជាប់ចោទ។ ជាឧទាហរណ៍ នួន ជា ទុកប្រមាណជា ១០០ទំព័រ - គឺច្រើនជាង មួយភាគបីនៃសារណារបស់គាត់ទាំងមូល - សម្រាប់ជាអំណះអំណាងលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ដែល អជតក ធ្លាប់បានកំណត់អត្តសញ្ញាណថាជាប់ពាក់ព័ន្ធទៅនឹងប្រធានបទនេះ។ ជាមួយគ្នានេះដែរ ជាការឆ្លុះបញ្ចាំងពីសារៈសំខាន់នៃប្រធានបទនេះ អជតក ធ្លាប់បានអនុញ្ញាតឲ្យពេលវេលាសរុបចំនួន១០០នាទី សម្រាប់ឲ្យជនជាប់ចោទធ្វើការលើកឡើងពីបញ្ហាទាំងនេះ។

៧. ប្រធានបទនេះបានក្លាយទៅជាការលេចធ្លោ នៅក្នុងកិច្ចដំណើរការនីតិវិធីនៃបណ្ដឹងសាទុក្ខនេះ ដែលជាលទ្ធផលមួយចេញមកពីភ័ស្តុតាងថ្មីដែលបានដាក់ជូន ហើយនិងអំណះអំណាងនានាដែលបានធ្វើឡើង នៅក្នុងបណ្ដឹងសាទុក្ខ។ ឥឡូវនេះ អជតក បានស្ដាប់ចម្លើយសាក្សី ហើយបានទទួលយកញត្តិស្នើសុំ ឲ្យទទួលយកភ័ស្តុតាងបន្ថែមដែល នួន ជា ប្រឈមដោះស្រាយ ថាជាមូលដ្ឋាននៃការទទួលខុសត្រូវជា បុគ្គលរបស់គាត់។ ការដាក់ជូនទាំងនេះ ក៏បានធ្វើឲ្យមានការបន្ថែម និងការកែប្រែយ៉ាងសំខាន់ផងដែរ ចំពោះអំណះអំណាងការពារនានា ដែលបានចែងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់។ ភ័ស្តុតាង ថ្មីដែលបានស្ដាប់ចំពោះបណ្ដឹងសាទុក្ខនេះ (ក៏ដូចជាភ័ស្តុតាងបន្ថែមណាមួយក៏ដោយដែល អជតក អាចនឹងទទួលយក) ហើយនិង អំណះអំណាងបន្ថែមសម្រាប់បណ្ដឹងសាទុក្ខរបស់ នួន ជា តាមពិតទៅគឺមិនត្រូវបានលើកឡើងទាំងនៅក្នុងសារណាសវនាការផ្ដាច់ព្រ័ត្ររបស់សហព្រះរាជអាជ្ញា និងទាំងនៅក្នុងចម្លើយតបទៅនឹងបណ្ដឹង

សាទុក្ខនោះទេ ដោយហេតុថាវាមិនមែនជាផ្នែកនៃកំណត់ត្រាសវនាការ។ ដូច្នេះ ចំពោះវិសាលភាព ដែល អជតក មានបំណងនឹងទទួលអំណះអំណាង និងភ័ស្តុតាងថ្មី យកមកធ្វើការពិចារណានោះ ការណ៍នេះ នឹងក្លាយទៅជាឱកាសតែមួយគត់សម្រាប់ឱ្យសហព្រះរាជអាជ្ញាធ្វើការលើកឡើងទៅជាផ្លូវការអំពីអត្ថន័យ និងសារៈសំខាន់នៃភ័ស្តុតាង និងអំណះអំណាងទាំងនេះ ឱ្យបានទូលំទូលាយ។ ដោយសារតែភាពលេចធ្លោនៃភ័ស្តុតាងថ្មីនេះមាននៅក្នុងទ្រឹស្តីនៃករណីរឿងក្តី របស់ នួន ជា ស្តីពីបណ្តឹងសាទុក្ខនោះ គាត់អាចត្រូវបានគេរំពឹងទុកថា មុខជានឹងទុកមួយផ្នែកធំសម្រាប់អំណះអំណាងផ្ទាល់មាត់របស់គាត់ចំពោះប្រធានបទនេះ។ សហព្រះរាជអាជ្ញា ត្រូវការឱកាសមួយដ៏គ្រប់គ្រាន់ដើម្បីធ្វើការឆ្លើយតប។

៨. សហព្រះរាជអាជ្ញា ក៏បានកត់សម្គាល់ផងដែរថា មានការត្រួតគ្នាខ្លះរវាង ទ្រឹស្តីរបស់ នួន ជា និង ទ្រឹស្តីរបស់ ខៀវ សំផន ទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល។ ជាឧទាហរណ៍ ខណៈដែល ខៀវ សំផន អាចនឹងមានការគាំទ្រយ៉ាងទូលំទូលាយដល់ទ្រឹស្តីការពារក្តីរបស់ នួន ជា ស្តីពីជម្លោះផ្ទៃក្នុងនៅក្នុង បកក នោះការដាក់ជូន និងអំណះអំណាងនានាដោយផ្ទាល់របស់ ខៀវ សំផន បានបញ្ជាក់ថា គាត់មានការជឿជាក់ជាបឋមអំពីមុខងាររបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺមិនសំខាន់គ្រប់គ្រាន់សមល្មមនឹងឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលទេ។ ម្យ៉ាងវិញទៀត នួន ជា ទទួលសារភាពថា គាត់គឺជាមេដឹកនាំដ៏សំខាន់មួយរូបក្នុងចំណោមមេដឹកនាំនានានៃកម្ពុជាប្រជាធិបតេយ្យ។ ជាលទ្ធផលនៃវិធីសាស្ត្រដែលខុសគ្នាទាំងនេះ សហព្រះរាជអាជ្ញាមិនអាចធ្វើការឆ្លើយតបយ៉ាងមានប្រសិទ្ធិភាព ទៅនឹងអំណះអំណាងនានារបស់ជនជាប់ចោទទាំងពីរនាក់នេះ ដែលទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល នៅពេលតែមួយជាមួយគ្នាបាននោះទេ ហើយសហព្រះរាជអាជ្ញាចាំបាច់ត្រូវតែធ្វើការលើកឡើងអំពីអំណះអំណាងនានារបស់ នួន ជា និង ខៀវ សំផន ដាច់ដោយឡែកពីគ្នា ដើម្បីធ្វើដូច្នេះបានចាំបាច់តម្រូវឱ្យមានពេលវេលាបន្ថែម។

៩. ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមស្នើថា ការផ្តល់ពេលវេលាជូនសហព្រះរាជអាជ្ញាសម្រាប់ប្រធានបទដែលលើកឡើងនេះ គួរត្រូវបានបង្កើនពី ៣៥ នាទី ទៅ ៨០ នាទី។

*ឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានកាត់ឱ្យជាប់ទោស*

១០. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ប្រធានបទដែលជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយដែលជនជាប់ចោទត្រូវបានកាត់ឱ្យជាប់ទោស ការពិតក៏ជាប្រធានបទស្មុគស្មាញមួយដែរ ដែលតម្រូវឱ្យសហ

ព្រះរាជអាជ្ញា គួរត្រូវទទួលបានការអនុសញ្ញាតបន្ថែមពេលវេលាសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។ អជតក បានកំណត់អត្តសញ្ញាណទឡ្ហីករណ៍ ១១៧ របស់ នួន ជា និង កថាខណ្ឌជាង ១០០ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថាមានការពាក់ព័ន្ធនឹងប្រធានបទនេះ[7]។ បញ្ហានានាដែលត្រូវបានគ្របដណ្តប់ដោយប្រធានបទនេះ មានចាប់ពីបញ្ហាទាំងឡាយដែលមានលក្ខណៈជាក់លាក់ និងផ្អែកលើអង្គហេតុដែលមានមូលដ្ឋានជាក់លាក់ ដូចជាការសម្លាប់បុគ្គលជាច្រើន[8] រហូតដល់បញ្ហាផ្នែកច្បាប់ទូទៅបំផុតដូចជាបញ្ហាថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានតំណភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធ[9] ជាដើម។ ជាថ្មីម្តងទៀត អំណះអំណាងរបស់ជនជាប់ចោទនៅលើប្រធានបទទាំងនេះ គឺផ្ទុយគ្នា។ ស្តែងចេញពីចំណុចនេះ និងសារសំខាន់នៃប្រធានបទនេះ អជតក បានផ្តល់ការអនុញ្ញាតឲ្យជនជាប់ចោទជាសរុបរួមចំនួន ៧០ នាទី ដើម្បីលើកអំពីបញ្ហាទាំងនេះ។ សហព្រះរាជអាជ្ញាសូមស្នើថា ការបែងចែកពេលវេលារបស់សហព្រះរាជអាជ្ញា គួរត្រូវបានបង្កើនពី ២៥នាទី ទៅ ៦០នាទី សម្រាប់ដោះស្រាយលើបញ្ហាអង្គហេតុ និងអង្គច្បាប់នៃបណ្តឹងសាទុក្ខដែលទាក់ទងនឹងប្រធានបទនេះ។

*សវនាការលើបណ្តឹងសាទុក្ខដែលមានលក្ខណៈជាសាធារណៈ*
*និងលទ្ធភាពនៃការផ្លាស់ប្តូរការកំណត់បទចោទចំពោះឧក្រិដ្ឋកម្ម*

១១. ខណៈដែលសហព្រះរាជអាជ្ញាសន្និដ្ឋានថា ការស្នើសុំពេលវេលាបន្ថែមរបស់ខ្លួន គឺជាការត្រឹមត្រូវទាំងស្រុង បើនិយាយអំពីភាពស្មុគស្មាញនៃបញ្ហាដែលត្រូវលើកក្នុងប្រធានបទនិមួយៗនោះ មានកត្តាបន្ថែមពីរក៏គាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញានេះដែរ។

---

[7] ឧបសម្ព័ន្ធ ក, ទំព័រ 01154379។

[8] *សូមមើល ជាឧទាហរណ៍* ឯកសារ **E313/1/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ២៩ កញ្ញា ២០១៤ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា"), ទឡ្ហីករណ៍៤៨-៩៦, ១៣៣, ១៤៦, ១៤៨-១៥០។

[9] **F17** សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១, ២៩ ធ្នូ ២០១៤ ("សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន"), ទឡ្ហីករណ៍៥២-៥៤។

១២. កត្តាបន្ថែមទីមួយ គឺលក្ខណៈនៃកិច្ចដំណើរការនីតិវិធីជាសាធារណៈនៅ អ.វ.ត.ក។ គឺមានផលប្រយោជន៍សាធារណៈយ៉ាងខ្លាំងនៅក្នុងដំណើរការនីតិវិធីដែលលក្ខណៈបើកចំហរ និងលទ្ធភាពពិនិត្យដែលអាចធ្វើទៅបានចំពោះសាធារណជន។ អាស្រ័យហេតុនេះ វាការជាសមស្របសម្រាប់ អជតក ពិចារណាអំពីផលប៉ះពាល់នៃតារាងពេលវេលារបស់ខ្លួន តាមលក្ខណៈនៃកិច្ចដំណើរការនីតិវិធីជាសាធារណៈ និងការយល់ដឹងរបស់សាធារណជនអំពីកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។ ការអនុញ្ញាតពេលវេលាតិចជាងពាក់កណ្តាលនៃពេលវេលាដែលជនជាប់ចោទទាំងពីរមាន ដើម្បីពិភាក្សាអំពីបញ្ហាគន្លឹះនានាចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ នឹងជួយសម្រុះសម្រួលដល់លទ្ធភាពរបស់សាធារណជនក្នុងការចូលពិនិត្យមើលកិច្ចដំណើរការនីតិវិធី និងហានិភ័យដែលនាំឲ្យសាធារណជនយល់ច្រឡំចំពោះភ័ស្តុតាងនានានៅក្នុងសំណុំរឿង និងបញ្ហាផ្សេងៗទៀតដែលកំពុងចោទឡើងនៅលើបណ្តឹងសាទុក្ខ។

១៣. ជាចុងក្រោយ សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា មានលទ្ធភាពមួយដែលនឹងតម្រូវឲ្យសហព្រះរាជអាជ្ញាអាចឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ស្តីពីភាពសមស្របនៃការផ្លាស់ប្តូរនៅក្នុងការកំណត់បទចោទចំពោះឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងនៃវគ្គសវនាការស្តីពីប្រធានបទទាំងពីរដែលសហព្រះកំពុងតែស្នើសុំពេលវេលាបន្ថែមនេះ[10]។ លទ្ធភាពនេះគឺជាកត្តាមួយផ្សេងទៀតដែលគាំទ្រចំពោះសំណើរបស់សហព្រះរាជអាជ្ញា។

## II. ដំណោះស្រាយដែលស្នើឡើង

១៤. ដូចមូលហេតុជំរាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

១) បង្កើនពេលវេលាដែលមានស្រាប់របស់សហព្រះរាជអាជ្ញា សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានស្តីពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលពី ៣៥ នាទី ទៅ ៨០ នាទី; ហើយនឹង

[10] ដីកា, ទំព័រ៥។

២) បង្កើនពេលវេលាដែលមានស្រាប់របស់សហព្រះរាជអាជ្ញា សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានស្តីពីឧក្រិដ្ឋកម្មនានាដែលជនជាប់ចោទត្រូវបានកាត់ឲ្យជាប់ទោសពី ២៥ នាទី ទៅ ៦០ នាទី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |